**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ១២០៤ ព.ណ.ឥ៖.វ.ស

ថ្ងៃ សុក្រ ៦ រោច ខែ ពិសាខ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០២១

# សេចក្តីជូនដំណឹង

## ស្តីពី

## ថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយ

- យោងប្រកាសអន្តរក្រសួងលេខ១៧២ពណ. អវង.ប្រក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និងថាមពល ស្តីពីការកំណត់រូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា
- យោងលើការព្រមព្រៀង លើរូបមន្តកំណត់តម្លៃជាមួយក្រុមហ៊ុនប្រេងឥន្ធនៈដែលប្រកបអាជីវកម្មនៅកម្ពុជា
- យោងការប្រែប្រួលនៃតម្លៃប្រេងឥន្ធនៈលើទីផ្សារក្នុងតំបន់ និងអន្តរជាតិ

ផ្អែកតាមតម្លៃមធ្យមប្រេងឥន្ធនៈលើទីផ្សារអន្តរជាតិ ថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី០១ ដល់ ១៥ ខែមិថុនា ឆ្នាំ ២០២១ នឹងត្រូវលក់ ៣.៩៦០រៀល/១លីត្រ សម្រាប់សាំងធម្មតា EA92 និង ៣.៦១០រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត។

ដើម្បីជួយសម្រួលដល់ជីវភាពរបស់ប្រជាជន និងដោយមានការរួមចំណែកពីក្រុមហ៊ុនចែកចាយប្រេងឥន្ធនៈនៅកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចបញ្ចុះតម្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា ចំនួន៤សេនដុល្លារ/លីត្រ ។

ដូច្នេះថ្លៃលក់រាយប្រេងឥន្ធនៈសម្រាប់អនុវត្ត **ចាប់ពីថ្ងៃទី០១ ដល់ ១៥ ខែមិថុនា ឆ្នាំ២០២១** នឹងចុះមក ៣.៨០០ រៀល/លីត្រ សម្រាប់សាំងធម្មតា EA92 និង ៣.៤៥០ រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត ។

ការគណនាថ្លៃលក់រាយប្រេងឥន្ធនៈមានលម្អិតដូចតារាងខាងក្រោម៖

**តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារកម្ពុជា**

| ល.រ | អធិប្បាយ | ប្រេងសាំងធម្មតា/លីត្រ (Gasoline 92) | ប្រេងម៉ាស៊ូត/លីត្រ (Gasoil) |
|---|---|---|---|
| ១ | **Average MOPS** | **០,៤៦៦៦ ដុល្លារ** | **០,៤៦៨២ ដុល្លារ** |
| ២ | **ពន្ធ៖** | **០,១៨៤៧ ដុល្លារ** | **០,០៧៤២ ដុល្លារ** |
| | ពន្ធគយ | ០,០៦៣៥ ដុល្លារ | ០,០០០០ ដុល្លារ |
| | អាករបន្ថែម | ០,០២០០ ដុល្លារ | ០,០៤០០ ដុល្លារ |
| | អាករពិសេស | ០,១០១៣ ដុល្លារ | ០,០៣៤២ ដុល្លារ |
| ៣ | **PREMIUM** | **០,២០ ដុល្លារ** | **០,២៣ ដុល្លារ** |
| ៤ | **អាករលើតម្លៃបន្ថែម (១០% នៃ ១+២+៣)** | **០,០៨៥១ ដុល្លារ** | **០,០៧៧២ ដុល្លារ** |
| ៥ | **ថ្លៃលក់រាយ/លីត្រ (គិតជាដុល្លារ)** | ០,៩៣៦៤ ដុល្លារ | ០,៨៤៩៧ ដុល្លារ |
| ៦ | **ថ្លៃលក់រាយ/លីត្រ (គិតជារៀល)** | ៣.៨១៦ រៀល | ៣.៤៦២ រៀល |
| ៧ | **តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជាដុល្លារ)** | **០,៩៤ ដុល្លារ** | **០,៨៥ ដុល្លារ** |
| ៨ | **តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជារៀល)** | **៣.៨០០ រៀល** | **៣.៤៥០ រៀល** |

**សម្គាល់៖** អត្រាប្តូរប្រាក់ផ្លូវការ ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ ដែលស្មើនឹង៤.០៧៥រៀល/ដុល្លារអាមេរិក

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

## តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ

| ថ្ងៃខែឆ្នាំ | ប្រេងសាំងធម្មតា/ធុង<br>EA 92 (USD/Barrel) | ប្រេងម៉ាស៊ូត/ធុង<br>Gasoil (USD/Barrel) |
|---|---|---|
| ១៧ ឧសភា ២០២១ | ៧៣,៦៦ | ៧៤,៩៥ |
| ១៨ ឧសភា ២០២១ | ៧៥,៥៨ | ៧៦,១៥ |
| ១៩ ឧសភា ២០២១ | ៧៣,៧៩ | ៧៤,១៥ |
| ២០ ឧសភា ២០២១ | ៧៣,៣៥ | ៧៣,៤៣ |
| ២១ ឧសភា ២០២១ | ៧១,០៤ | ៧១,៣៤ |
| ២៤ ឧសភា ២០២១ | ៧៤,១៦ | ៧៤,១៦ |
| ២៥ ឧសភា ២០២១ | ៧៥,២៥ | ៧៥,០៨ |
| ២៧ ឧសភា ២០២១ | ៧៤,៥៥ | ៧៤,៤៩ |
| ២៨ ឧសភា ២០២១ | ៧៥,៧៦ | ៧៥,២២ |
| ៣១ ឧសភា ២០២១ | ៧៤,៦៩ | ៧៥,៤៦ |
| **មធ្យមភាគ ១០ថ្ងៃ** | **៧៤,១៨៣០** | **៧៤,៤៤៦០** |
| **មធ្យមភាគ (ដុល្លារ/លីត្រ)** | **០,៤៦៦៦** | **០,៤៦៨២** |

### ក្រាហ្វិកបម្រែបម្រួលថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី១៦ ខែមីនា ដល់ ០១ ខែមិថុនា ឆ្នាំ២០២១




សូមបញ្ជាក់ថា ក្រសួងពាណិជ្ជកម្មមិនមែនជាអ្នកកំណត់ថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជាទេ គឺក្រសួងគ្រាន់តែស្រង់តម្លៃឡើង-ចុះ នៃប្រេងតាមទីផ្សារអន្តរជាតិ មកគណនាតាមប្រកាសដូចមានក្នុងឯកសារយោងខាងលើតែប៉ុណ្ណោះ ។

អាស្រ័យហេតុនេះ សូមសាធារណៈជនមេត្តាជ្រាបជាព័ត៌មាន និងសូមគ្រប់ស្ថានីយលក់រាយប្រេងឥន្ធនៈទាំងអស់ប្រតិបត្តិតាមការចាំបាច់។